# ថ្ងៃឈប់សម្រាក និងសាក្រាម៉ង់

អែលឌើរ អិល ថម ភែរី
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់

*សូមឲ្យគ្រួសាររបស់អ្នក បានពោរពេញដោយក្តីស្រឡាញ់ នៅពេលអ្នកគោរពថ្ងៃឈប់សម្រាកពេញមួយថ្ងៃ ហើយទទួលបទពិសោធន៍ពរជ័យខាងវិញ្ញាណពេញមួយសប្តាហ៍ ។*

បងប្អូនប្រុសស្រីរបស់ខ្ញុំនៅទូទាំងពិភពលោក ព្រឹកនេះយើងបានមកស្តាប់សម្លេងរបស់ព្យាការី ។ ខ្ញុំថ្លែងទីបន្ទាល់ថា សម្លេងដែលយើងទើបតែបានស្តាប់នោះ គឺជាសម្លេងរបស់ព្យាការីនៅរស់របស់ព្រះ នៅលើផែនដីសព្វថ្ងៃនេះ ជាប្រធានថូម៉ាស អេស ម៉នសុន ។ យើងមានពរណាស់តាមរយៈការបង្រៀន និងគំរូរបស់លោក !
ឆ្នាំនេះយើងមានឱកាសសិក្សាពាក្យសម្តីរបស់ព្យាការីនៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។ ខណៈដែលគម្ពីរសញ្ញាចាស់ សិក្សាអំពីព្យាការី និងប្រជាជនមួយក្រុមនោះព្រះគម្ពីរសញ្ញាថ្មី បានផ្តោតទៅលើជីវិត និងឥទ្ធិពលរបស់បុរសតែម្នាក់គត់ ដែលមកក្នុងជីវិតរមែងស្លាប់ មានសញ្ជាតិពីរ នៅស្ថានសួគ៌ផង និងផែនដីផង —ជាព្រះអង្គសង្គ្រោះ និងព្រះប្រោសលោះរបស់យើង ព្រះយេស៊ូវគ្រីស្ទ ។

ពិភពលោកសព្វថ្ងៃនេះ គឺជោរជន់ទៅដោយគោលលទ្ធិរបស់មនុស្ស ដែលងាយនឹងបំភ្លេច ហើយបាត់បង់ជំនឿលើអ្វីៗដែលជារឿងសំខាន់អំពីជីវិត និងការបម្រើរបស់ព្រះអង្គសង្គ្រោះ —ក្នុងព្រះគម្ពីរសញ្ញាថ្មី ។ ព្រះគម្ពីរពិសិដ្ឋនេះ គឺផ្តោតទៅលើប្រវត្តិសាស្រ្តព្រះគម្ពីរ ដូចជាព្រះអង្គសង្គ្រោះផ្ទាល់ គឺជាចំណុចសំខាន់នៃជីវិតរស់នៅរបស់យើង ។ យើងត្រូវតែតាំងចិត្តដើម្បីសិក្សា និងទុកវាជារតនៈសម្បត្តិ !

យើងអាចរកមុក្តានៃប្រាជ្ញាដែលមានតម្លៃមិនអាចកាត់ថ្លៃបាននៅក្នុងការសិក្សាព្រះគម្ពីរសញ្ញាថ្មី ។ ខ្ញុំតែងតែចូលចិត្តអានដំណើររឿងរបស់ប៉ុល នៅពេលគាត់បានធ្វើដំណើរ និងរៀបចំសាសនាចក្រ ជាពិសេសការបង្រៀនរបស់គាត់ទៅកាន់ប្រជាជនធីម៉ូថេ ។ ក្នុងជំពូកទីបួននៃការសរសេររបស់ប៉ុលទៅកាន់ប្រជាជនធីម៉ូថេ យើងអានថា ៖

« ចូរផ្តាំគេពីសេចក្តីទាំងនេះ ហើយបង្ហាត់បង្រៀនចុះ ចូរធ្វើជាគំរូដល់ពួកអ្នកជឿ ដោយពាក្យសម្តី កិរិយាប្រព្រឹត្ត សេចក្តីស្រឡាញ់ សេចក្តីជំនឿ និងសេចក្តីបរិសុទ្ធ » ។[1] ខ្ញុំនឹកមិនឃើញពីផ្លូវណាដែលល្អជាងនេះសម្រាប់យើងឡើយ ក្នុងការចាប់ផ្តើម ឬការបន្តធ្វើជាគំរូនៃពួកអ្នកជឿ នៅក្នុងការរក្សាថ្ងៃឈប់សម្រាករបស់យើងនោះ ។

តាំងពីការបង្កើតលោកិយ មានមួយថ្ងៃត្រូវបានញែកចេញពីថ្ងៃផ្សេងៗ ។ « ព្រះទ្រង់ក៏ប្រទានពរដល់ថ្ងៃទី 7 នោះ » ។[2] សូម្បីតែព្រះទ្រង់សម្រាកពីការងារនៅថ្ងៃនេះ ហើយទ្រង់រំពឹងចង់ឲ្យកូនចៅរបស់ទ្រង់ធ្វើដូចគ្នាដែរ ។ ចំពោះកូនចៅអ៊ីស្រាអែល ទ្រង់បានផ្តល់បញ្ញត្តិថា ៖

« ចូរឲ្យនឹកចាំពីថ្ងៃឈប់សម្រាក ដើម្បីញែកថ្ងៃនោះចេញជាបរិសុទ្ធ ។ ក្នុងរវាង 6 ថ្ងៃ នោះត្រូវឲ្យឯងធ្វើអស់ទាំងការរបស់ឯងចុះ តែថ្ងៃទី 7 នោះគឺជាថ្ងៃឈប់សម្រាកថ្វាយ ព្រះអម្ចាស់ជាព្រះនៃឯងវិញ ... ហេតុនោះបានជាព្រះយេហូវ៉ាទ្រង់បានប្រទានពរដល់ថ្ងៃឈប់សម្រាក ហើយក៏ញែកចេញជាបរិសុទ្ធ » ។[3]

គំរូនៃការរក្សាថ្ងៃឈប់សម្រាក ត្រូវតែមានការថ្វាយបង្គំជានិច្ច ។ បន្ទាប់ពីលោកអ័ដាម និងនាងអេវ៉ាបានចូលមកក្នុងភាពរមែងស្លាប់ ពួកគេត្រូវបានបញ្ជាឲ្យ « ថ្វាយបង្គំព្រះអម្ចាស់ជាព្រះរបស់ពួកគេ ហើយគប្បីយកកូនសត្វច្បងនៃហ្វូងចៀមរបស់គេមកថ្វាយជាយញ្ញបូជាទាំងឡាយដល់ព្រះអម្ចាស់ ...ជានិមិត្តរូបអំពីការបូជានៃព្រះរាជបុត្រាបង្កើតតែមួយនៃព្រះវរ -បិតា » ។[4] ការថ្វាយយញ្ញបូជាសត្វបានរំឭកដល់កូនចៅអ័ដាមថា នៅថ្ងៃមួយ កូនចៀមនៃព្រះ ព្រះយេស៊ូវគ្រីស្ទ នឹងលះបង់ព្រះជន្មរបស់ទ្រង់សម្រាប់យើង ។

នៅក្នុងឆាកជីវិតរបស់ទ្រង់ ព្រះអង្គសង្គ្រោះមានបន្ទូលអំពីការពលិកម្មនោះ ។[5] ពេលទ្រង់ត្រូវគេឆ្កាង បន្ទូលរបស់ទ្រង់ត្រូវបានបំពេញ ។ ពេលកូនសិស្សរបស់ទ្រង់មកជួបជុំគ្នានៅបន្ទប់ខាងលើ ឆ្ងាយពីការរំខាននៃលោកិយ ទ្រង់បានរៀបចំសាក្រាម៉ង់នៃអាហារពេលយប់របស់ព្រះ -អម្ចាស់ ។ « គ្រាដែលកំពុង

តែបរិភោគ នោះព្រះយេស៊ូវទ្រង់យកនំបុ័ង ហើយកាលទ្រង់បានប្រទានពរ នោះក៏កាច់ប្រទានទៅពួកសិស្ស ដោយបន្ទូលថា ចូរយកបរិភោគចុះ នេះហើយជារូបកាយខ្ញុំ ។ រួចទ្រង់យកពែងមកប្រទានពរ ក៏ហុចទៅឲ្យគេ ដោយបន្ទូលថា ចូរបរិភោគពីពែងនេះទាំងអស់គ្នាចុះ ត្បិតនេះជាឈាមខ្ញុំ គឺជាឈាមនៃសញ្ញាថ្មី ដែលបានច្រួចចេញ សម្រាប់មនុស្សជាច្រើន ប្រយោជន៍នឹងផ្តាច់បាប » ។ [6]

ចាប់តាំងពីគ្រានោះមក ដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ ក្លាយជាការបូជាដ៏មហិមា និងជាពលិកម្មចុងក្រោយ ។ នៅពេលទ្រង់យាងមកទ្វីបអាមេរិក បន្ទាប់ពីការរស់ឡើងវិញ ទ្រង់បានប្រគល់បព្វជិតភាពរបស់ទ្រង់ដល់ពួកសិស្សរបស់ទ្រង់ ហើយបានណែនាំពីពិធីសាក្រាម៉ង់ ដោយមានព្រះបន្ទូលថា « ហើយការណ៍នេះ អ្នករាល់គ្នាត្រូវធ្វើជានិច្ច គឺដូចដែលយើងបានកាច់ ហើយប្រទានពរនំបុ័ង ហើយចែកដល់អ្នករាល់គ្នា ... ។ ហើយការណ៍នេះនឹងទៅជាទីបន្ទាល់ដល់ព្រះវរបិតាថា អ្នករាល់គ្នាចងចាំដល់យើងជានិច្ច ។ ហើយបើសិនជាអ្នករាល់គ្នាចងចាំយើងជានិច្ច នោះអ្នករាល់គ្នានឹងមានព្រះវិញ្ញាណរបស់យើងនៅជាមួយនឹងអ្នក » ។ [7]

នេះគឺជារឿងអស្ចារ្យដែលសូម្បីតែនៅក្នុងគ្រាខ្មៅងងឹតនៃការក្បត់សាសនា ក៏គំរូនៃការថ្វាយបង្គំក្នុងថ្ងៃឈប់សម្រាក និងសាក្រាម៉ង់នេះបានបន្តអនុវត្តតាមរបៀបផ្សេងៗជាច្រើន ។ នៅពេលដំណឹងល្អ ត្រូវបានស្តាឡើងវិញ មានសាវកបីរូប ពេត្រុស យ៉ាកុប និងយ៉ូហាន ដែលបានទទួលសាក្រាម៉ង់មកពីព្រះអង្គសង្គ្រោះដំបូងគេ បានលេចមកឯយ៉ូសែប ស្ម៊ីធ និងអូលីវើ ខៅឌើរី ក្រោមការដឹកនាំរបស់ពួកគាត់ សិទ្ធិអំណាចបព្វជិតភាពដែលចាំបាច់ដើម្បីចាត់ចែងដល់ពិធីសាក្រាម៉ង់ដល់សមាជិកសាសនាចក្ររបស់ព្រះយេស៊ូវគ្រីស្ទត្រូវបានស្តារឡើងវិញ។ [8]

ដោយបានប្រគល់ពីព្រះអង្គសង្គ្រោះដល់ពួកព្យាការី និងពួកសាវករបស់ទ្រង់ ហើយចេញពីពួកគាត់មកយើង សិទ្ធិអំណាចបព្វជិតភាពនោះនៅបន្តមានលើផែនដីសព្វថ្ងៃនេះ ។ ពួកអ្នកកាន់បព្វជិតភាពវ័យក្មេងនៅទូទាំងពិភពលោក មានគុណសម្បត្តិនឹងអនុវត្តអំណាចបព្វជិតភាព តាមរយៈការគោរពតាមបទបញ្ញត្តិដោយអស់ពីចិត្ត និងរស់នៅតាមបទដ្ឋានដំណឹងល្អ ។ នៅពេលយុវជនទាំងនេះ រក្សាដៃស្អាតស្អំ និងដួងចិត្តបរិសុទ្ធខាងវិញ្ញាណ ពួកគេរៀបចំប្រសិទ្ធពរ និងចែកសាក្រាម៉ង់តាមរបៀបរបស់ព្រះអង្គសង្គ្រោះ --ជាវិធីមួយដែលកំណត់តាមអ្វីដែលទ្រង់បានធ្វើ កាលពីជាងពីរពាន់ឆ្នាំកន្លងទៅ ។

ការទទួលទានសាក្រាម៉ង់ គឺសំខាន់ក្នុងការញែកថ្ងៃឈប់សម្រាករបស់យើងឲ្យបរិសុទ្ធ ។ នៅក្នុងគោលលទ្ធិ និងសេចក្តីសញ្ញា ព្រះអម្ចាស់បញ្ជាដល់យើងគ្រប់គ្នាថា ៖ « ហើយប្រយោជន៍ឲ្យអ្នករាល់គ្នាអាចរក្សាខ្លួនឲ្យបានពេញលេញ កុំឲ្យប្រឡាក់ពីលោកិយ នោះអ្នកត្រូវទៅដំណាក់នៃការអធិស្ឋាន ហើយថ្វាយសាក្រាម៉ង់របស់អ្នកឡើង នៅថ្ងៃបរិសុទ្ធរបស់យើងចុះ ។ ត្បិតប្រាកដមែន ថ្ងៃនេះត្រូវបានចាត់ទុកដល់អ្នក ដើម្បីឲ្យសម្រាកពីការងារទាំងឡាយរបស់អ្នក ហើយដើម្បីថ្វាយភក្តីភាពរបស់អ្នកដល់ព្រះដ៏ខ្ពស់បំផុត ... ។ ហើយអ្នកមិនត្រូវធ្វើអ្វីឡើយ » ។ [9]

នៅពេលយើងពិចារណាអំពីគំរូនៃថ្ងៃឈប់សម្រាក និងសាក្រាម៉ង់នៅក្នុងជីវិតផ្ទាល់របស់យើង មានរឿងបីយ៉ាង ដែលព្រះអម្ចាស់តម្រូវពីយើង ។ ទីមួយការរក្សាខ្លួនយើងកុំឲ្យប្រឡាក់ពីលោកិយ ។ ទីពីរ ការទៅដំណាក់នៃការអធិស្ឋាន ហើយថ្វាយសាក្រាម៉ង់របស់យើងឡើង ។ ហើយទីបី គឺការសម្រាកពីការងារទាំងឡាយរបស់យើង ។ វាគឺជារឿងដ៏មានកិត្តិយស ដើម្បីធ្វើជាពួកគ្រីស្ទានម្នាក់ រស់នៅជាសិស្សពិតប្រាកដរបស់ព្រះគ្រីស្ទ ។ ទ្រង់មានបន្ទូលអំពីយើងថា « គេមិនមែនជារបស់ផងលោកិយ ដូចជាទូលបង្គំក៏មិនមែនជារបស់លោកិយដែរ » ។ [11] ដើម្បីរក្សាខ្លួនយើងកុំឲ្យប្រឡាក់ពីលោកិយ ទ្រង់សង្ឃឹមថាយើងចៀសវាងពីការរំខាននៃលោកិយ ខាងជំនួញ និងពីអ្វីៗដែលសប្បាយនៅថ្ងៃឈប់សម្រាក ។
ខ្ញុំជឿថា ទ្រង់ក៏មានព្រះទ័យចង់ឲ្យយើងស្លៀកពាក់សមរម្យដែរ ។យុវវ័យរបស់យើងអាចគិតពីពាក្យពីដើមថា « សំលៀកបំពាក់ស្អាតថ្ងៃអាទិត្យ » ហួសសម័យ ។ ប៉ុន្តែយើងដឹងថា នៅពេលសំលៀកបំពាក់ថ្ងៃអាទិត្យមិនសមរម្យ នោះសំលៀកបំពាក់រាល់ថ្ងៃ អាកប្បកិរិយា និងសកម្មភាពទាំង -ឡាយក៏មិនសមរម្យតាមនោះដែរ ។ ប្រាកដណាស់ វាអាចនឹងមិនចាំបាច់សម្រាប់កូនៗរបស់យើងស្លៀកសំលៀកបំពាក់ថ្ងៃអាទិត្យ រហូតដល់ព្រះអាទិត្យលិចនោះទេ ។ ទោះជាយ៉ាងណាក៏ដោយ តាមរយៈសំលៀកបំពាក់ យើងលើកទឹកចិត្តពួកគេឲ្យស្លៀកពាក់ ហើយនៅក្នុងសកម្មភាពដែលយើងរៀបចំ យើងជួយពួកគេរៀបចំសម្រាប់សាក្រាម៉ង់ និងរីករាយចំពោះពរជ័យទាំងឡាយពេញមួយថ្ងៃនោះ ។

តើការថ្វាយសាក្រាម៉ង់របស់យើងឡើងថ្វាយព្រះអម្ចាស់ មានន័យយ៉ាងណា ? យើងទទួលស្គាល់ថា យើងទាំងអស់គ្នាបានធ្វើខុសឆ្គង ។ យើង ម្នាក់ៗចាំបាច់ត្រូវសារភាព ហើយលះបង់អំពើបាប និងកំហុសរបស់យើងចំពោះព្រះវរបិតាសួគ៌របស់យើង និងអ្នកដទៃដែលយើងធ្វើឲ្យអាក់អន់ចិត្ត ។ ថ្ងៃឈប់សម្រាកផ្តល់ឲ្យយើងនូវឱកាសដ៏មានតម្លៃ ដើម្បីថ្វាយរឿងទាំងនេះ ---សាក្រាម៉ង់របស់យើង --ថ្វាយដល់ព្រះអម្ចាស់ ។ ទ្រង់មានបន្ទូលថា « ប៉ុន្តែចូរនឹកចាំថា នៅថ្ងៃនេះ ជាថ្ងៃរបស់ព្រះអម្ចាស់ អ្នកត្រូវថ្វាយដង្វាយទាំងឡាយរបស់អ្នក និងសាក្រាម៉ង់ទាំងឡាយរបស់អ្នកដល់ព្រះដ៏ខ្ពស់បំផុត ដោយសារភាពនូវអំពើបាបទាំងឡាយរបស់អ្នកដល់បងប្អូនរបស់អ្នក និងនៅចំពោះព្រះអម្ចាស់ចុះ » ។ [11]

អែលឌើរ មេលវិន ជី បាឡាដ បានឲ្យយោបល់ថា « យើងចង់ឲ្យពួកបរិសុទ្ធថ្ងៃចុងក្រោយគ្រប់រូបមកកាន់តុសាក្រាម៉ង់ ដោយសារវាគឺជាកន្លែងសម្រាប់ការអង្កេតមើលខ្លួនឯង សម្រាប់ការត្រួតពិនិត្យខ្លួនឯង ជាកន្លែងដែលយើងអាចរៀន ដើម្បីកែទិសដៅរបស់យើង ហើយធ្វើត្រឹមត្រូវសម្រាប់ជីវិតរបស់យើង នាំខ្លួនយើងឲ្យស្រុបតាមការបង្រៀនរបស់សាសនាចក្រ និងជាមួយបងប្អូនប្រុសស្រីរបស់យើង » ។ [12]

នៅពេលយើងសក្តិសមទទួលទានសាក្រាម៉ង់ យើងធ្វើជាសាក្សីថា យើងយល់ព្រមទទួលយកព្រះនាមនៃព្រះអង្គសង្គ្រោះមកដាក់លើខ្លួនយើង ហើយកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ និង*ចងចាំ* ទ្រង់ជានិច្ច ដើម្បីយើងអាចមានព្រះវិញ្ញាណរបស់ទ្រង់នៅជាមួយយើង ។ តាមរបៀបនេះ យើងរំឭកសេចក្តីសញ្ញានៃពិធីបុណ្យជ្រមុជទឹករបស់យើង ។ ព្រះ -អម្ចាស់បានអះអាងនឹងសិស្សទ្រង់ថា « នៅពេលអ្នកធ្វើការណ៍នេះញឹកញាប់ នោះអ្នកនឹងចងចាំម៉ោងនេះដែលយើងនៅជាមួយនឹងអ្នក » ។ [13]

ពេលខ្លះ យើងគិតអំពីការសម្រាកពីការងាររបស់យើង ដោយគ្រាន់តែដាក់កណ្តាប់បញ្ឈរចោលនៅក្នុងស្រែ និងការដាក់ផ្លាកសញ្ញាថា « បិទ » នៅលើទ្វារហាង ។ ប៉ុន្តែពិភពលោកសព្វថ្ងៃ ការងាររួមមានកិច្ចការប្រចាំថ្ងៃក្នុងជីវិតរបស់យើង ។ ការណ៍នេះអាចមានន័យថា ជាសកម្មភាពអាជីវកម្ម ដែលយើងអាចសម្រេចបាននៅផ្ទះ ការប្រណាំងអត្តពលកម្ម និងការខិតខំដទៃទៀត ដែលនាំយើងចេញពីការថ្វាយបង្គំនៅថ្ងៃឈប់សម្រាក និងឱកាសដើម្បីបម្រើដល់អ្នកដទៃ ។

ព្រះអម្ចាស់បានបើកសម្តែងដល់ពួកបរិសុទ្ធជំនាន់មុនថា « ចូរកុំប្រហែសនឹងការណ៍ដ៏ពិសិដ្ឋទាំងឡាយឡើយ » [14] ជាការរំឭកដល់យើងអំពីអ្វីដែលទ្រង់បានប្រាប់ដល់ពួកសិស្ស «ថ្ងៃឈប់សម្រាកបានតាំងសម្រាប់ឲ្យមនុស្ស មិនមែនជាមនុស្សសម្រាប់ថ្ងៃឈប់សម្រាកទេ » ។ [15]

បងប្អូនប្រុសស្រី នៅក្នុងថ្ងៃចុងក្រោយនេះ សត្រូវមានជោគជ័យ ពេលយើងមិនសូវតាំងចិត្តរបស់យើងចំពោះព្រះអង្គសង្គ្រោះ មិនខ្វល់អំពីការបង្រៀនរបស់ទ្រង់នៅក្នុងគម្ពីរសញ្ញាថ្មី និងគម្ពីរផ្សេងទៀត ហើយឈប់ដើរតាមទ្រង់ ។ ឪពុកម្តាយទាំងឡាយ ឥឡូវនេះគឺជាពេលដើម្បីបង្រៀនកូនៗរបស់យើងឲ្យធ្វើជាគំរូនៃពួកអ្នកជឿ តាមរយៈការចូលរួម ក្នុងការប្រជុំសាក្រាម៉ង់ ។ នៅពេលព្រឹកថ្ងៃអាទិត្យមកដល់ សូមជួយពួកគេឲ្យសម្រាកបានល្អ ស្លៀកពាក់សមរម្យ និងរៀបចំខ្លួនខាងវិញ្ញាណ ដើម្បីទទួលទាននិមិត្តរូបនៃសាក្រាម៉ង់ និងទទួលការបំភ្លឺ ការស្អាង អំណាចតម្កើងនៃព្រះវិញ្ញាណបរិសុទ្ធ ។ សូមឲ្យគ្រួសាររបស់អ្នក បានពោរពេញដោយក្តីស្រឡាញ់ នៅពេលអ្នកគោរពថ្ងៃឈប់សម្រាកពេញមួយថ្ងៃ ហើយទទួលបទពិសោធន៍ពរជ័យខាងវិញ្ញាណពេញមួយសប្តាហ៍ ។ សូមអញ្ជើញកូនប្រុសស្រីរបស់អ្នកឲ្យ« ក្រោកឡើង ហើយបញ្ចាំងពន្លឺចេញទៅ » តាមរយៈការរក្សាថ្ងៃឈប់សម្រាកឲ្យបរិសុទ្ធ ដើម្បី « ប្រយោជន៍ឲ្យពន្លឺរបស់[ ពួកគេ ] អាចបានទៅជាបមាណីយដល់សាសន៍នានា » ។ [16]

ជាច្រើនឆ្នាំបានកន្លងទៅ ខ្ញុំបន្តរំឭកអំពីថ្ងៃឈប់សម្រាក កាលពីខ្ញុំនៅជា យុវវ័យ និងពេលធំឡើង ។ ខ្ញុំនៅតែចាំពីថ្ងៃដំបូង ដែលខ្ញុំបានបម្រើ សាក្រាម៉ង់ក្នុងនាមជាឌីកុនម្នាក់ និងចាំអំពីកូនកែវតូចៗចែកទៅដល់សមាជិកវួដ ។ កាលពីប៉ុន្មានឆ្នាំមុន អគារសាសនាចក្រ ត្រូវបានសាងសង់ឡើងវិញនៅទីក្រុងរបស់ខ្ញុំ តំបន់វេទិកាត្រូវបានបិទជិត ។ នៅពេលវាបានបើកវិញ នោះមានកូនកែវតូចៗ កប់លាក់នៅរាប់ឆ្នាំ ។ ខ្ញុំទទួលបានកែវមួយទុកជាអនុស្សាវរីយ៍ ។

ខ្ញុំនៅចាំផងដែរអំពីហឹបពណ៌បៃតងដែលយើងយកទៅជាមួយយើងនៅក្នុងក្រុមនាវិក ។ នៅខាងក្នុងហឹបនោះមានថាសឈើនិងកញ្ចប់កែវសាក្រាម៉ង់ជាច្រើន ដើម្បីយើងអាចបានទទួលពរដោយក្តីសុខសាន្ត និងក្តីសង្ឃឹម នៃអាហារជប់លៀងរបស់ព្រះអម្ចាស់ ទោះបីជានៅក្នុងជម្លោះ និងភាពអស់សង្ឃឹមនៃសង្គ្រាមក្តី ។

នៅពេលខ្ញុំគិតអំពីពែងសាក្រាម៉ង់កាលពីខ្ញុំនៅយុវវ័យ ជ្រលងភ្នំដែលជាទីជម្រកមួយនៃផ្ទះ កាលពីក្មេងរបស់ខ្ញុំ ដែលមានចម្ងាយរាប់ពាន់គីឡូពីមហាសមុទ្រប៉ាស៊ីហ្វិក ខ្ញុំមានអំណរគុណណាស់ ដែលព្រះអង្គសង្គ្រោះនៃពិភពលោកបានស្ម័គ្រព្រះទ័យដើម្បីផឹក« ពែងល្វីង » [17] សម្រាប់ប្រយោជន៍ខ្ញុំ ។ ហើយដោយសារទ្រង់បានធ្វើដូច្នោះ ខ្ញុំអាចនិយាយជាមួយនឹងទំនុកតម្កើងថា « ពែងនៃទូលបង្គំក៏ពេញហៀរ » ជាមួយនឹងពរជ័យនៃដង្វាយធួនដ៏និរន្ត និងនៅដ៏អស់កល្បជានិច្ចរបស់ទ្រង់ ។

នៅថ្ងៃនេះ មុនថ្ងៃឈប់សម្រាក នៅពេលយើងចាប់ផ្តើមសន្និសីទដ៏ធំនេះ សូមយើងចាំនូវពរជ័យ និងឱកាសដែលយើងមាន នៅពេលយើងចូលរួមការប្រជុំសាក្រាម៉ង់រាល់សប្តាហ៍នៅក្នុងវួដ និងសាខារបស់យើង ។ ចូរយើងរៀបចំខ្លួន ហើយដឹកនាំខ្លួនក្នុងថ្ងៃឈប់សម្រាកតាមរបៀបមួយដែលនឹងទាញពរជ័យទាំងឡាយ ដែលបានសន្យាដល់យើង និងគ្រួសាររបស់យើង ។ ខ្ញុំថ្លែងជាសាក្សីដ៏ពិសេសថា ក្តីអំណរដ៏មហិមាបំផុតដែលយើងទទួលនៅក្នុងជីវិតនេះកើត

មានតាមរយៈការធ្វើតាមព្រះអង្គសង្គ្រោះ ។ ចូរយើងកាន់តាមព្រះបញ្ញត្តិរបស់ទ្រង់ ដោយការរក្សាថ្ងៃពិសិដ្ឋទ្រង់ឲ្យបរិសុទ្ធ នេះជាការអធិស្ឋានរបស់ខ្ញុំ ក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន ។

កំណត់ចំណាំ


1. ធីម៉ូថេទី 1 4:11–12
2. លោកុប្បត្តិ 2:3
3. និក្ខមនំ 20:8–11
4. ម៉ូសេ 4:5,7
5. ឧទាហរណ៍ រួមមាន ម៉ាកុស 10:32–34, យ៉ូហាន 2:29, 10:17, 12:32
6. ម៉ាថាយ 26:26–28
7. នីហ្វៃទី 3 18:6–7
8. សូមមើល គ. និង ស. 27:12–13
9. គ. និង ស. 59:9–10, 13
10. យ៉ូហាន 17:16
11. គ. និង ស. 59:12
12. Bryant S. Hinckley, Sermons និង Missionary Services of Melvin Joseph Ballard [ Salt Lake City: Deseret Book Co. ឆ្នាំ 1949 ] ទំព័រ 150
13. ម៉ាកុស 14:21 ក.យ.ស.
14. គ. និង ស. 6:12
15. ម៉ាកុស 2:27
16. គ. និង ស. 115:5
17. នីហ្វៃទី 3 11:11
18. ទំនុកដំកើង 23:5